## សរុបព្រឹត្តការណ៍ប្រចាំថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០
## សម្រាប់ វីរុស COVID-19

# ១. រស្មីកម្ពុជា៖ ប្រធាន WHO : ពិភពលោក ត្រូវតែត្រៀមខ្លួនសម្រាប់លទ្ធភាពនៃជំងឺឆ្លងរាតត្បាតគ្រប់កន្លែង

រស្មីកម្ពុជា





សុខភាព-អប់រំផ្លូវភេទ | សុខភាពទូទៅ | ព័ត៌មានអន្តរជាតិ




## ប្រធាន WHO : ពិភពលោក ត្រូវតែត្រៀមខ្លួនសម្រាប់លទ្ធភាពនៃជំងឺឆ្លងរាតត្បាតគ្រប់កន្លែង

February 25, 2020, 9:05 AM 72

អង្គការសុខភាពពិភពលោកកាលពីថ្ងៃចន្ទ ទី២៤ កុម្ភៈ បាននិយាយថា ការរីករាលដាលនៃវីរុសកូរ៉ូណាថ្មីបានកើនឡើងដល់ "កម្រិតខ្ពស់បំផុត" នៅក្នុងប្រទេសចិន ប៉ុន្តែបានព្រមានថា ការកើនឡើងករណីថ្មីក្នុងប្រទេស ផ្សេងទៀតគឺគួរឱ្យព្រួយបារម្ភខ្លាំង ហើយប្រទេសទាំងអស់គួរតែត្រៀមខ្លួនសម្រាប់ "លទ្ធភាពជំងឺរាតត្បាតគ្រប់ទីកន្លែង"។




*ប្រធានWHO និយាយថា Coviv-19 នៅតែអាចបង្ក្រាបបាន ហើយវាមិនទាន់ដល់ពេលប្រកាសការឆ្លងរាតត្បាតសលកនៅឡើយទេ*

ប្រធានអង្គការសុខភាពពិភពលោក (WHO) លោក ថេដ្រូស អាដាណុម ហ្គេប្រេយេ៉ស៊ូស បាននិយាយថា ការឆ្លងមេរោគដល់ចំណុចកំពូលនៅក្នុង ប្រទេសចិនបានកើតឡើងនៅចន្លោះថ្ងៃទី ២៣ ខែមករាដល់ថ្ងៃទី ២ ខែកុម្ភៈ ហើយចំនួនករណីថ្មីនៅទីនោះបានធ្លាក់ចុះជាលំដាប់ចាប់តាំងពីពេលនោះមក។

លោកបានប្រាប់អ្នកយកព័ត៌មាននៅទីក្រុងហ្សឺណែវថា "វីរុសនេះអាចទប់ស្កាត់ បាន" ដោយកោតសរសើរចិនដែលបានជួយទប់ស្កាត់ការរីករាលដាល កាន់តែធំឡើងនៃវីរុសតាមរយៈការបិទក្រុងមិនធ្លាប់មានពីមុនមកនិងការដាក់ឱ្យនៅដាច់ឆ្ងាយពីចំណុចកណ្តាល នៅកន្លែងផ្ទុះមេរោគ។

ការកើនឡើងករណីឆ្លងវីរុសកូរ៉ូណានៅប្រទេសផ្សេងទៀតលើពិភពលោក បានជំរុញឱ្យមានវិធានការស្រដៀងគ្នានេះដែរ។ ប្រទេសអ៊ីតាលីបានបិទទីប្រជុំជន ចំនួន ១១ ហើយកូរ៉េខាងត្បូងបានបញ្ជាឱ្យប្រជាជនចំនួន ២,៥ លាននាក់នៃ ទីក្រុងដេគូស្ថិតនៅក្នុងផ្ទះ។

វីរុសកូរ៉ូណាក៏បានបណ្តាលឱ្យធ្លាក់ចុះជាង ៣,០ ភាគរយនៅក្នុងផ្សារហ៊ុនអឺរ៉ុប ជាច្រើនផងដែរ ដោយផ្សារហ៊ុនមីឡង់បានធ្លាក់ចុះ ៥,៤ ភាគរយនិងការលក់មាស បានកើនឡើង ចំពេលមានការបារម្ភថាការរីករាលដាលនៃជំងឺនេះ អាចជះផលប៉ះពាល់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។

ការរីករាលដាលនៃមេរោគដែលគេស្គាល់ជាផ្លូវការថា កូវីដ១៩ បានបន្តឥត ស្រាកស្រាន្ត ខណៈប្រទេសអាហ្វហ្គានីស្ថាន បារ៉ែន អ៊ីរ៉ាក់ កូវ៉ែត និង អូម៉ង់ បានប្រកាសករណីដំបូងរបស់ពួកគេកាលពីថ្ងៃចន្ទ។

ចិនក៏បានបន្តវិធានការទប់ស្កាត់វីរុសនេះផងដែរកាលពីថ្ងៃចន្ទ ដោយពន្យារ ពេលកិច្ចប្រជុំសភាប្រចាំឆ្នាំជាលើកដំបូង ចាប់តាំងពីបដិវត្តន៍វប្បធម៌ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០៕ ដោយ៖ កញ្ញាដាលីស/Ha

## ២. កោះសន្តិភាព៖ វីរុស Covid-19 ចំពេលមានការភ័យខ្លាចថា អ្នកគាំទ្របាល់ទាត់អាចឆ្លងវីរុសនេះ នៅពេលទៅទស្សនាការប្រកួត

KOH SANTEPHEAP MEDIA

Tiger STREET FOOTBALL 2020
ស្វែងចេញនូវការតាំងចិត្ត ដ៏មោះមុតរបស់អ្នក
UNCAGE YOUR TIGER
$50,000



# ក្លិបPremier Leagueចាប់ផ្តើមវិធានការការពារវីរុសCovid-19

ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៩:១៩ វិៈបុត្រ Share



តាមការអង្កេតកាលពីថ្ងៃអាទិត្យ បានបង្ហាញនៅថាក្លិបក្នុងក្របខ័ណ្ឌ Premier League កំពុងតែប្រុងប្រយ័ត្នយ៉ាងខ្លាំង ចំពោះវិបត្តិពិភពលោកជាមួយវីរុស Covid-19 ចំពេលមានការភ័យខ្លាចថា អ្នកគាំទ្របាល់ទាត់អាចឆ្លងវីរុសនេះ នៅពេលទៅទស្សនាការប្រកួត នេះជាក់ស្តែង ក្នុងប្រកួតរបស់ក្រុម Crystal Palace គេសង្កេតឃើញមានការព្រួយបារម្ភយ៉ាងខ្លាំងនៅកីឡដ្ឋាន Selhurst Park របស់ក្លិប ដោយបានចាត់វិធានការជាបន្ទាន់ ដល់អ្នកចូលរួមទាំងអស់តម្រូវឱ្យពាក់ម៉ាសការពារ នឹងត្រូវលាងសម្អាតដៃឱ្យបានញឹកញាប់ និងវិធានការជាច្រើនទៀត ដើម្បីការពារកីឡាករ បុគ្គលិក រួមទាំងអ្នកគាំទ្រពីវីរុសដ៏កាចសាហាវនេះ។

ស្របពេលដែលអ្នកស្លាប់ដោយសារវីរុសនេះបានកើនដល់ជិត ២,៧០០នាក់ និងអ្នកឆ្លងឡើងដល់ជាង ៨,០០០០ករណីនៅជុំវិញពិភពលោក ។ ប្រភព៖ The Sun

អត្រាប្តូរប្រាក់
ប្រាក់រៀល (1USD) | KHR 1USD : 4087
អត្រាប្តូរប្រាក់ផ្សេងទៀត ›
SPONSORED NEWS



# ៣.កោះសន្តិភាព៖ ប្រកួតទាំងអស់នៅSerie A អាចនឹងត្រូវបន្តពន្យារដោយសារវីរុសCovid-19




ទំព័រមុខ ▸ ព័ត៌មានកីឡា ▸ កីឡាអន្តរជាតិ ▸ ប្រកួតទាំងអស់នៅSerie A អាចនឹងត្រូវបន្តពន្យារដោយសារវីរុសCovid-19

## ប្រកួតទាំងអស់នៅSerie A អាចនឹងត្រូវបន្តពន្យារដោយសារវីរុសCovid-19

ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៩:១៣ វិរៈបុត្រ

Share Like 28



នាយករដ្ឋមន្ត្រីអ៊ីតាលីបានបញ្ជាក់ថា ការប្រកួតទាំងអស់នៅលីគកំពូលអ៊ីតាលី Serie A នៅចុងសប្តាហ៍នេះ អាចនឹងត្រូវបន្តពន្យារពេលទៀត ដោយសារវិបត្តិវីរុសឆ្លង Covid-19 ។ នេះបើតាមការចុះផ្សាយប្រភពពី The Sun។

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
| --- | --- |

អត្រាប្តូរប្រាក់ផ្សេងទៀត ›

SPONSORED NEWS



០៣:៣២ | ក្នុងស្រុក

ម្ចាស់ផ្ទះតាកែវ City Bird (A) ក្លាយជាជើងឯកមណ្ឌលតាកែវ នៃព្រឹត្តិការណ៍ Tiger Street Football 2020



០៩:៣៥ | ក្នុងស្រុក

នាយករដ្ឋមន្ត្រីអ៊ីតាលីលោក Giuseppe Conte បានបង្ហើបឱ្យដឹងថាលោកកំពុងពិចារណាពន្យាពេលរាល់ការប្រកួតទាំងអស់នៅក្របខ័ណ្ឌ Serie A នៅចុង សប្តាហ៍នេះ។ រលឹកថា ការប្រកួតចំនួន៤នៃក្របខ័ណ្ឌ Serie A ត្រូវបានលុបចោលកាលពីថ្ងៃអាទិត្យកន្លងទៅ។

ដោយមានករណីឆ្លងវីរុសនេះនៅប្រទេសអ៊ីតាលីជាង ១៥២ករណី នាយករដ្ឋមន្ត្រីរូបនេះអាចត្រូវបង្ខំចិត្តឱ្យមានវិធានការធ្ងន់ធ្ងរបន្ថែមទៀត ។ លោកបាននិយាយថា «ខ្ញុំមិនគិតថាក្នុងមួយសប្តាហ៍ យើងនឹងអាចកាត់បន្ថយការឆ្លងបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យយើងបន្តព្រឹត្តិការណ៍កីឡាឡើងវិញនោះទេ។យើងនឹងតាមដានស្ថានការណ៍ជានិច្ច។




នៅពេលនេះខ្ញុំមិនអាចនិយាយបានទេថា តើយើងនឹងបន្តវិធានការដូចគ្នានៅសប្តាហ៍ក្រោយ ឬយ៉ាងណា? យើងកំពុងពិចារណាពន្យារពេលការប្រកួតទាំងអស់»។ការពន្យារពេលនេះគឺនៅចំ ការប្រកួតដ៏ធំប្រចាំសប្តាហ៍នៃក្របខ័ណ្ឌ Serie A រវាងក្រុម Juventus ទល់នឹងក្រុម Inter Milan ផងដែរ។ ប្រភព៖ The Sun

## ៤. វិទ្យុហង្សមាសៈ




## ៥. រស្មីកម្ពុជាៈ ទូតម៉ាឡេស៊ីចូលបំភ្លឺជូនក្រសួងការបរទេសកម្ពុជារឿងថាស្ត្រីអាមេរិកអាយុ៨៣ឆ្នាំមានជំងឺកូរ៉ូណា




ទូតម៉ាឡេស៊ីចូលបំភ្លឺជូនក្រសួងការបរទេសកម្ពុជារឿងថាស្ត្រីអាម៉េរិកអាយុ៨៣ឆ្នាំមានជំងឺកូរ៉ូណា

February 25, 2020, 7:32 PM 51

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ អគ្គរាជទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជាលោក Eldeen Hasaaini bin Mohd Hashim បានចូលបំភ្លឺជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅរសៀលថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២០ នេះ នៅទីស្តីការក្រសួងការបរទេស។

នៅក្នុងការចូលមកបំភ្លឺនេះ គឺអគ្គរាជទូតម៉ាឡេស៊ី បានធ្វើការបំភ្លឺជូនលោកស្រី ទូត បញ្ញា អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ការចូលបំភ្លឺរបស់អគ្គរាជទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជា បានធ្វើឡើងមួយថ្ងៃ បន្ទាប់ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាជំរុញឱ្យរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា កោះហៅអគ្គរាជទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជាចូលបំភ្លឺពាក់ព័ន្ធនឹងករណីដែលរដ្ឋាភិបាលម៉ាឡេស៊ីប្រកាសថា ស្ត្រីជនជាតិអាម៉េរិកាំង អាយុ៨៣ឆ្នាំ ជាអ្នកដំណើរតាមនាវាទេសចរណ៍ Westerdam ដែលចាកចេញពីកម្ពុជានោះ មានជំងឺកូរ៉ូណាថ្មី ( Covid-19 ) ហើយត្រូវបានម៉ាឡេស៊ីព្យាបាលជា រយៈពេល៧២ម៉ោង ប៉ុន្តែករណីនេះផ្ទុយស្រឡះពីមជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺឆ្លងរបស់សហរដ្ឋអាមេរិក (USCDC) ដែលប្រកាសថា ស្ត្រីជនជាតិអាមេរិកាំង គ្មានផ្ទុកមេរោគ Covid-19 គ្រាន់តែអាចមានជំងឺសួតធម្មតា។

លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងប្រាប់រស្មីកម្ពុជាកាលពីព្រលប់ថ្ងៃទី២៥ ខែកុម្ភៈ ថា “កាលពីរសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ អគ្គរាជទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជាបានចូលមកបំភ្លឺជាមួយលោកជំទាវ ទូត បញ្ញា អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ការចូលមកបំភ្លឺនេះ ពាក់ព័ន្ធស្ត្រីអាម៉េរិកាំងអាយុ៨៣ឆ្នាំ ដែលកន្លងមកម៉ាឡេស៊ីប្រកាសថា ម្តងថាមានវីរុស Covid-19 ម្តងថាអត់មានវិញ ហើយដែលមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជម្ងឺរបស់សហរដ្ឋអាមេរិក (CDC) បានប្រកាសថា ជនជាតិអាម៉េរិកកាំងទាំងអស់ រួមទាំងស្ត្រីអាម៉េរិកកាំង អាយុ៨៣ឆ្នាំ មិនមានការឆ្លងមេរោគនឹងទេ។ ហើយការបំភ្លឺ គឺជុំវិញរឿងនឹង”។

ជុំវិញការចូលបំភ្លឺរបស់ឯកអគ្គរាជទូតម៉ាឡេស៊ី អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា មិនបានធ្វើអត្ថាធិប្បាយលម្អិត នៃការចូលបបំភ្លឺនេះទេ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានបង្ហាញនូវការសោកស្តាយចំពោះឧបនាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ីដែលជាប្រពន្ធរបស់លោក អាន់វ៉ា អ៊ីប្រាហ៊ីម អតីតមេបក្សប្រឆាំងនៃប្រទេសម៉ាឡេស៊ីដែលបានចេញមកប្រកាស ថាស្ត្រីម្នាក់ជនជាតិអាមេរិកអាយុ ៨៣ ឆ្នាំដែលចេញពីនាវា Werstedam មានឆ្លងមេរោគ Covid-19 ។ ប្រតិកម្មរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីត្រូវបាន ធ្វើឡើងបន្ទាប់ពីសហរដ្ឋអាមេរិកបានប្រកាសថា ជនជាតិអាមេរិកនៅលើនាវា Werstedamទាំងអស់មិនមានឆ្លងវិរុស Covid-19 រាប់ទាំងស្ត្រីអាយុ៨៣ ឆ្នាំ ដែលត្រូវម៉ាឡេស៊ីប្រកាសថាមានឆ្លងមេរោគCovid-19 ផងដែរ ។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសបែបនេះនៅ ព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ នៅវិមានសន្តិភាពទីស្តីការនាយករដ្ឋមន្ត្រីក្នុងឱកាសសន្និសីទសារព័ត៌មាន ស្តីពីវិធានការរបស់រាជរដ្ឋាភិបាលដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (ខូវីដ-១៩) និង ការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ក្រោមកម្មវិធី «ទំនិញគ្រប់មុខ លើកលែងអាវុធ» (EBA)។
សម្តេចតេជោនាយករដ្ឋមន្ត្រីបានថ្លែថា «បញ្ហានេះបានដាក់បន្ទុកឲ្យយើងនៅការខាតបង់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ជាតិរបស់យើងអ្នកខ្លះគិតថារឿងនេះជារឿងស្រាលប៉ុន្តែពលរដ្ឋកម្ពុជាមិនចាត់ទុកថាជារឿងស្រាលទេ»៕

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្ថែមថា ប្រសិនបើសម្តេចជានាយករដ្ឋមន្ត្រីម៉ាឡេស៊ី សម្តេចនឹងដករដ្ឋមន្ត្រីសុខាភិបាលនេះចេញព្រោះជាការធ្វើការខ្ជីខ្ជា ក្នុងការទទួលខុសត្រូវដែលប៉ះពាល់ ៤១ សញ្ជាតិដែលមកពី ៤១ ប្រទេសដែលទទួលផលប៉ះពាល់នេះ ។ សម្តេចតេជោបានបញ្ជាក់ទៀតថា សម្តេចមិន ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ម៉ាឡេស៊ីទេ។ ក៏ប៉ុន្តែប្រទេសម៉ាឡេស៊ីតាមរយៈមនុស្សមួយចំនួនបានបង្កើតនូវហេតុការណ៍ដក់ជាប់សម្រាប់កកម្ពុជាទម្រាំបានមកវិញនូវយុត្តិធម៌តាមរយៈសេចក្តីប្រកាសថាពេលនេះអត់មានវីរុសកូរ៉ូណាទេ ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើងទៀតថាបើសិនជា មនុស្សនេះត្រូវបានព្យាបាលជា ពិភពលោកគួរតែបានមករៀនសូត្រពីម៉ាឡេស៊ីព្រោះព្យាបាលត្រឹមតែ ៧២ ម៉ោងជាវាជារឿងអស្ចារ្យណាស់ជាអភូតហេតុ មួយដែលគួរកោតសរសើរចំពោះវេជ្ជសាស្ត្ររបស់ម៉ាឡេស៊ី។
សម្តេចតេជោបានបន្តថា សម្តេចសង្ឃឹមថានាយករដ្ឋមន្ត្រីមហាធាលោកនឹងយល់អំពីអារម្មណ៍មួយនេះប្រសិនបើគាត់គិតគូរទៅដល់កិត្តិយសជាតិសាសន៍របស់គាត់ហើយសង្ឃឹមថា រដ្ឋមន្ត្រីការបរទេសកម្ពុជាលោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នឹងកោះហៅឯកអគ្គរដ្ឋទូតម៉ាឡេស៊ីទៅធ្វើការបំភ្លឺលើរឿងនេះព្រោះឥឡូវម៉ាកប៉ាល់ទាំងអស់អត់មានអ្នកណាមួយមានជំងឺនេះសោះហើយអ្វីដែលសំខាន់ជាងនេះទៅទៀតប្តីរបស់គាត់អត់មានឆ្លងតើហេតុអ្វីប្រពន្ធឆ្លង។
សម្តេចតេជោបានបន្តថា តើម៉ាឡេស៊ីត្រូវគិតយ៉ាងម៉េចចំពោះបញ្ហានេះមិនមែនបញ្ហាកិត្តិយសរបស់កម្ពុជាតែម្នាក់នោះទេកិត្តិយសសម្រាប់៤១ជាតិសាស ន៍ក្នុងនោះអាមេរិកច្រើនជាងគេអាមេរិកមានរហូត ៦៥០នាក់ ។ ឥឡូវអាមេរិកប្រកាសចេញថាពួកទេសចរអាមេរិកទាំងអស់នោះមិនមានកើតវីរុសកូរ៉ូណា ទេ,វេជ្ជសាស្ត្រអាមេរិកខ្លាំងហើយយើងមិនបានប្រកាសតែម្នាក់ឯងទេអង្គការសុខភាពពិភពលោក វិទ្យាស្ថានប៉ាស្ទ័រ និងអាមេរិកក៏បានចូលរួមជាមួយក្នុង ការពិនិត្យមិនមែនកម្ពុជាធ្វើតែម្នាក់ឯងទេ ៕

# ៦. រស្មីកម្ពុជា៖ ពួកមហាសេដ្ឋីពិភពលោកខាតសរុបរួមគ្នា ១៣៩ ពាន់លានដុល្លារក្នុងពេលតែមួយថ្ងៃដោយសារវីរុសកូរ៉ូណា



ក្នុងប្រទេស ⌄ អន្តរជាតិ ⌄ កម្សាន្ត ⌄ សុខភាព ⌄ បច្ចេកវិទ្យា-វិទ្យាសាស្ត្រ ⌄ កីឡា ⌄ ចំណេះដឹងទូទៅ ⌄ ប្លែកៗ ⌄ ស្រាវជ្រាវ ⌄ បទវិភាគ ⌄

ព័ត៌មានអន្តរជាតិ

## ពួកមហាសេដ្ឋីពិភពលោកខាតសរុបរួមគ្នា ១៣៩ ពាន់លានដុល្លារក្នុងពេលតែមួយថ្ងៃដោយសារវីរុសកូរ៉ូណា

February 25, 2020, 4:09 PM

48




ការវិវឌ្ឍនេះកើតឡើងស្របពេលអង្គការសុខភាពពិភពលោកបាននិយាយថាវីរុសកូរ៉ូណាមានលទ្ធភាពប្រែក្លាយទៅជាជំងឺរាតត្បាតនិងជំរុញឱ្យសហគមន៍អន្តរជាតិត្រូវប្រឹងប្រែងបន្ថែមទៀតដើម្បីត្រៀមខ្លួនសម្រាប់សេណារីយ៉ូបែបនេះ។

អ្នកមានបំផុតចំនួន ៥០០ នាក់នៅលើពិភពលោកបានខាតបង់ប្រាក់រួមគ្នាសរុប ១៣៩ ពាន់លានដុល្លារក្នុងពេលតែមួយថ្ងៃដោយសារតែការធ្លាក់ចុះយ៉ាងខ្លាំងនៅលើទីផ្សារហិរញ្ញវត្ថុពិភពលោកដែលបណ្តាលមកពីការផ្ទុះឡើងនៃវីរុសកូរ៉ូណា។

ការកើនឡើងនូវករណីថ្មីនៅខាងក្រៅប្រទេសចិនបានបង្កឱ្យមានការព្រួយបារម្ភក្នុងចំណោមវិនិយោគិនថាការរីករាលដាលនៃវីរុសនេះនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោកចុះខ្សោយ។ ជាលទ្ធផល កាលពីថ្ងៃចន្ទទី២៤កុម្ភៈ ផ្សារហ៊ុន S&P 500 និង Dow Jones បានប្រកាសពីការធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលជាងពីរឆ្នាំដោយស្រុតចុះ ៣,៥ ភាគរយ។ ផ្សារហ៊ុន Nasdaq បានធ្លាក់ចុះ ៣,៧ ភាគរយ ខណៈផ្សារហ៊ុនក្រុងមីឡង់ធ្លាក់ចុះ ៦ ភាគរយ ដោយសារព័ត៌មានថាចំនួនអ្នកឆ្លងវីរុសនេះនៅអ៊ីតាលីបានកើនឡើងដល់ ២២៩ នាក់។

ភាពវឹកវរនៅលើទីផ្សារហ៊ុនបានបណ្តាលឱ្យធ្លាក់ចុះទ្រព្យសម្បត្តិរបស់ពួកមហាសេដ្ឋីមានជាងគេបំផុតនៅលើពិភពលោក។ អ្នកមានបំផុតនៅលើពិភពលោកនិងជាប្រធានក្រុមហ៊ុន Amazon លោក ជេហ្វ បេហ្សូស បានខាតបង់ជាង ៤,៨ ពាន់លានដុល្លារ។ ដូចលោកបេហ្សូសដែរ មហាសេដ្ឋីបារាំងលោក ប៊ីណាត អាណុល ប្រធានក្រុមហ៊ុន LVMH ដែលជាក្រុមហ៊ុនផលិតទំនិញប្រណីត បានខាតបង់អស់ ៤,៨ ពាន់លានដុល្លារ។ លោក អាម៉ាស៊ីអូ អូតេហ្គា នាយកប្រតិបត្តិក្រុមហ៊ុនម៉ូតសម្លៀកបំពាក់ល្បី Inditex ឈរនៅលេខ ២ ដោយខាតបង់ ៤ ពាន់លានដុល្លារ ចំណែកឯទ្រព្យសម្បត្តិរបស់អ្នកផ្សេងទៀតដែលស្ថិតក្នុងកំពូលតារាងទាំង១០ បានធ្លាក់ចុះយ៉ាងហោចណាស់ ២,៣ ពាន់លានដុល្លារក្នុងម្នាក់ៗ៕ ដោយ៖ កញ្ញាដាលីស

# ៧. រស្មីកម្ពុជា៖ប្រទេស៤ថៃមទៀតនៅមជ្ឈិមបូព៌ា រាយការណ៍អំពីករណីឆ្លងវីរុសCOVID-19








ព័ត៌មានអន្តរជាតិ

## ប្រទេស៤ថៃមទៀតនៅមជ្ឈិមបូព៌ា រាយការណ៍អំពីករណីឆ្លងវីរុស COVID-19

February 25, 2020, 10:10 AM

63




វីរុសCOVID-19នេះ បានឆ្លងនៅប្រទេសចំនួន៤ថៃមទៀតនៅតំបន់មជ្ឈិមបូព៌ាកាលពីថ្ងៃចន្ទទី២៤កុម្ភៈ ដោយប្រទេស បារ៉ែន អ៊ីរ៉ាក់ គុយវ៉ែត និងអូម៉ង់ រាយការណ៍ពីករណីឆ្លងថ្មីនិងប្រទេសអេមីរ៉ាតអារ៉ាប់រួម អំពាវនាវកុំឱ្យពលរដ្ឋរបស់ខ្លួនធ្វើដំណើរទៅអ៊ីរ៉ង់និងថៃ។

គុយវ៉ែតបានលុបចោលពិធីអបអរសាទរថ្ងៃបុណ្យជាតិរបស់ខ្លួនដែលគ្រោងធ្វើនៅថ្ងៃអង្គារនិងថ្ងៃពុធ ស្របពេលដែលខ្លួនបានបញ្ជាក់អំពីករណីឆ្លងវីរុសចំនួន៣ ករណីដំបូងរបស់ខ្លួន ដែលករណីទាំងអស់នេះបានទាក់ទងទៅនឹងប្រទេសអ៊ីរ៉ង់។

អូម៉ង់បានបញ្ឈប់ការហោះហើរទៅនិងមកពីអ៊ីរ៉ង់ដែលកំពុងប្រយុទ្ធប្រឆាំងការផ្ទុះឡើងនៃវីរុសដ៏ប្រល័យនេះ នៅក្រៅប្រទេសចិន ។

ចំណាត់ការនេះបានធ្វើឡើងភ្លាមៗបន្ទាប់ពីស្ត្រីអូម៉ង់២នាក់ដែលបានវិលត្រឡប់មកពីប្រទេសអ៊ីរ៉ង់ ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺនេះ។

ករណីទាំង៣នៅប្រទេសគុយវ៉ែតនិងមួយករណីនៅប្រទេសបារ៉ែនក៏ជាបុគ្គលដែលបានវិលត្រឡប់មកពីប្រទេសអ៊ីរ៉ង់ ជាទីដែលវីរុសនេះបានសម្លាប់មនុស្ស១២នាក់។

ក្រសួងសុខាភិបាលបារ៉ែនបាននិយាយថា ប្រទេសបារ៉ែនបានបិទទ្វារសាលាចំនួន៣ បន្ទាប់ពីបុរសម្នាក់ដែលបានដឹកកុមារទៅសាលារៀនបានធ្វើតេស្តិ៍វិជ្ជមាននៃវីរុសនេះ បន្ទាប់ពីបានត្រឡប់មកពីប្រទេសអ៊ីរ៉ង់ កាលពីថ្ងៃទី២១ ខែកុម្ភៈកាត់តាមអាកាសយានដ្ឋានក្រុងឌុយបៃ។

នៅប្រទេសគុយវ៉ែត ជនជាតិគុយវ៉ែតម្នាក់អាយុ៥៣ឆ្នាំ ជនជាតិអេមីរ៉ាតអារ៉ាប់រួមម្នាក់អាយុ៦១ឆ្នាំនិងជនជាតិអារ៉ាប់អាយុ២១ឆ្នាំដែលបានធ្វើតេស្តិ៍វិជ្ជមាននៃវីរុសនេះ បានមកពីទីក្រុងម៉ាសហាត ប្រទេសអ៊ីរ៉ង់។

ក្រសួងសុខាភិបាលអ៊ីរ៉ាក់ បាននិយាយថា នៅអ៊ីរ៉ាក់វីរុសនេះត្រូវបានបញ្ជាក់ថាមាននៅលើជនជាតិអ៊ីរ៉ង់ម្នាក់ដែលកំពុងសិក្សានៅទីក្រុងណាចាហ្វភាគខាងត្បូងនៃប្រទេសអ៊ីរ៉ាក់៕ប្រែសម្រួល៖*សុខា/sn*/Ha

# ៨. កម្ពុជាថ្មី៖ក្រសួងទេសចរណ៍ ចុះផ្សព្វផ្សាយវិធានការបង្ការការចម្លងជំងឺរលាកសួតរ៉ូសក្សូវ៉ីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ២០១៩(Covid-19) សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍


កម្ពុជាថ្មី ប្រចាំថ្ងៃ KAMPUCHEA THMEY DAILY

សេវាឥណទាន

ទំព័រដើម | ព័ត៌មាន | KPT PLUS | កម្សាន្ត | កីឡា | សុខភាព | បច្ចេកវិទ្យា | ហោរាសាស្ត្រ

Amret mobile ចុចទីនេះដើម្បីទាញយក Available on the App Store | Get it on Google play


Home › ព័ត៌មានជាតិ › ការអភិវឌ្ឍ › ក្រសួងទេសចរណ៍ ចុះផ្សព្វផ្សាយវិធានការបង្ការការចម្លងជំងឺរលាកសួតវីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ២០១៩(Covid-19) សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍



## ក្រសួងទេសចរណ៍ ចុះផ្សព្វផ្សាយវិធានការបង្ការការចម្លងជំងឺរលាកសួតវីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ២០១៩(covid-19) សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

25/2/2020 3:47 Pm ការអភិវឌ្ឍ, ជាតិទូទៅ, ទេសចរណ៍, ព័ត៌មានជាតិ LIKE


ADVERTISER








សៀមរាប ៖ លោក ឈុន មករា អគ្គលេខាធិការរងគជវទ និងជា ប្រធាននាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារនីកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីវិធានការបង្ការការចម្លងជំងឺរលាកសួតវីរុសកូរ៉ូណាប្រភេទថ្មី២០១៩(Covid-2019) សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដោយផ្សារភ្ជាប់ពិធីផ្សព្វផ្សាយកម្មវិធីប្រលងប្រណាំងពានរង្វាន់មគ្គុទ្ទេសក៍ទេសចរណ៍លំដាប់ពិភពលោក( Wanderlust World Guide Award 2020) និងវគ្គបណ្តុះបណ្តាលស្តីពីបំណកស្រាយអាថ៌កំបាំងនៃព្រៃក្សត្រ និងមូលដ្ឋានគ្រឹះនៃការថតរូបតាមរយៈSmart Phone ក្នុងគោលបំណងពង្រឹងស្មារតី និងអភិវឌ្ឍន៍សមត្ថភាពបន្ថែមសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងដំណាក់កាល និងក្រោយវិបត្តិនៃជំងឺកូរ៉ូណា។

ឯកឧត្តមបានជម្រាបថា កម្ពុជាជាគោលដៅមានសុខសុវត្ថិភាព ប៉ុន្តែស្នើសុំឲ្យមគ្គុទ្ទេសក៍បង្កើនស្មារតីប្រុងប្រយ័ត្ន និងពិសេស ត្រូវចូលរួមយ៉ាងសកម្មរាយការណ៍ពីស្ថានភាពមិនប្រក្រតីណាមួយដែលកើតមានលើភ្ញៀវទេសចរ។ ម្យ៉ាងទៀត ត្រូវ បន្តពង្រឹងនិងពង្រីកសមត្ថភាពបន្ថែម ដើម្បីចាប់យកឱកាសក្រោយវិបត្តិ។

# ៩. កម្ពុជាថ្មី៖អប់រំផ្សព្វផ្សាយពីការថែទាំសុខភាព និងវិធីការពារជំងឺវីរុសកូរ៉ូណា ឬកូវីដ១៩ និងជំងឺទឹកនោមផ្អែម

KAMPUCHEA THMEY DAILY

















## អប់រំផ្សព្វផ្សាយពីការថែទាំសុខភាព និងវិធីការពារជំងឺវីរុសកូរ៉ូណា ឬកូវីដ ១៩ និងជំងឺទឹកនោមផ្អែម

25/2/2020 11:50 Pm ជាតិទូទៅ, ព័ត៌មានជាតិ, សុខភាព


ADVERTISER








ភ្នំពេញ ៖ ខណៈមានការភ្ញាក់ផ្អើល និងបារម្ភខ្លាំងពីជំងឺតាមផ្លូវដង្ហើមដោយវីរុសកូរ៉ូណា ឬកូវីដ១៩ដែលបានផ្ទុះឡើង និងឆ្លងរាលដាលជុំវិញពិភពលោក និងស្របពេលដែលជំងឺទឹកនោមផ្អែមបាន និងកំពុងកើតមានយ៉ាងខ្លាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរនោះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ បានរៀបចំសិក្ខាសាលាមួយ ដើម្បីអប់រំផ្សព្វផ្សាយថែទាំសុខភាព និងវិធីការពារជំងឺទាំងពីរនេះ ដែលពិធីនេះបានធ្វើឡើង កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ នៅសាលារាជធានីភ្នំពេញ ក្រោមវត្តមាន លោកជួប ឌុន សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ លោកស្រីឃួន គីមនី ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារនៃក្រុមប្រឹក្សារាជធានីភ្នំពេញ និង លោកឌី មានហេង ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីបងប្អូនស្ត្រីប្រមាណជាង៥០០នាក់ មកពីខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ។

លោកជួប ឌុន បានមានប្រសាសន៍លើកឡើងថា អង្គសិក្ខាសាលាអប់រំផ្សព្វផ្សាយ ថែទាំស្តីពីវិធីការពារជំងឺទឹកនោមផ្អែម បង្ការជំងឺឆ្លងវីរុសកូរ៉ូណាថ្មី ឬកូវីដ១៩ របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី៣នេះធ្វើឡើងដើម្បីអបអរសាទរទិវាអន្តរជាតិនារី៨មិនាឆ្នាំ២០២០ ក្រោមប្រធានបទ មានសន្តិភាពមានការលើកកម្ពស់សមភាពយេនឌ័រ ស្របពាក្យស្លោក "អរគុណសន្តិភាព"។

លោកជួប ឌុន បានមានប្រសាសន៍បន្តថា ការចូលរួមរបស់បងប្អូនស្ត្រី ក្នុងអង្គសិក្ខាសាលានាថ្ងៃនេះ គឺសុទ្ធសឹងជាធនធានមនុស្សរបស់រាជធានីភ្នំពេញ ដែលសំខាន់នោះ គឺការយល់ដឹងអំពីវិធីបង្ការការពារ និងថែទាំសុខភាព ដើម្បីសុខភាពរឹងមាំចូលរួមអភិវឌ្ឍន៍ប្រទេសជាតិមាតុភូមិ ក៏ដូចជារាជធានីភ្នំពេញឲ្យកាន់តែរីកចម្រើនជាលំដាប់។ ក្រៅពីនេះ លោកក៏បានសម្តែងការកោតសរសើរដោយស្មោះចំពោះគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ ដែលបានតាំងចិត្ត និងការខិតខំប្រឹងប្រែងសហការជាមួយមន្ទីរសុខាភិបាលរាជធានី បង្កើតព្រឹត្តិការណ៍អបអរសាទរទិវាអន្តរជាតិ៨មិនា រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយការថែទាំសុខភាព មានន័យថា យើងមិនត្រឹមតែបានលើកអំពីសិទ្ធិរបស់ស្ត្រីទេ តែយើងបានយល់ដឹងបន្ថែមទៀតនៅការបង្ការ ការពារ និងការថែទាំសុខភាពផ្ទាល់ខ្លួនរបស់យើងគ្រប់គ្នា ព្រមទាំងសម្រាប់ក្រុមគ្រួសារ ញាតិមិត្ត និងបងប្អូនប្រជាពលរដ្ឋយើងនៅក្នុងមូលដ្ឋានថែមទៀត។

លោកបន្តទៀតថា យើងទាំងអស់គ្នាមិនថាស្ត្រី ឬបុរសទេ គឺមានមួយចំនួនបាន និងកំពុងកើតជំងឺ និងមានមួយចំនួនទៀត នឹងមានហានិភ័យ នៃជំងឺទឹកនោមផ្អែមដែរ ដែលយើងចាំបាច់ត្រូវដឹងពីវិធីការពារ និងថែទាំសុខភាពឲ្យបានប្រសើរ។ ម្យ៉ាងទៀតនៅពេលថ្មីៗនេះ មានការភ្ញាក់ផ្អើល និងព្រួយបារម្ភខ្លាំងពីការចម្លងជំងឺផ្លូវដង្ហើមដោយវីរុសកូរ៉ូណាថ្មី ដែលទើបតែផ្ទុះនឹងឆ្លងរាលដាលជុំវិញពិភពលោកមានប្រភពដើមពីទីក្រុងWUHAN ប្រទេសចិន ដែលយើងទាំងអស់គ្នាត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងទប់ស្កាត់ការឆ្លងនេះ បើទោះបីប្រជាពលរដ្ឋនៃប្រទេសកម្ពុជាយើងពុំទាន់រកឃើញថា មាននរណាម្នាក់ផ្ទុកវីរុសនេះក៏ដោយ។

លោកឌី មានហេង ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញក្នុងឱកាស នៃការធ្វើបទបង្ហាញ នៃជំងឺទាំងពីរនេះ បានលើកឡើងថា កង្វះការធ្វើពលកម្មដូចជា មិនមានការហាត់ប្រាណ មិនដើរច្រើន វាជាដើមចម បង្កើតឲ្យមានជំងឺទឹកនោមផ្អែម ជំងឺបេះដូង និងជំងឺមហារីក។ ដូច្នេះទេ លោកស្នើឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបង្ការជំងឺទឹកនោមផ្អែមឲ្យបានល្អ ដោយត្រូវហាត់ប្រាណឲ្យបានច្រើន មានរបបអាហារត្រឹមត្រូវ ជាមួយនឹងការរក្សាទម្ងន់កុំលើសច្រើន។ មានន័យថា បើយើងមានកម្ពស់ ១ម៉ែត្រ៥០ ត្រូវមានទម្ងន់៥០គីឡូក្រាម ១ម៉ែត្រ៦០ មានទម្ងន់៦០គីឡូក្រាម ឬ ១ម៉ែត្រ៧០ មានទម្ងន់ស្មើនឹង៧០គីឡូក្រាមជាដើម។

# ១០.កម្ពុជាថ្មី៖ស្ថានទូតខ្មែរប្រចាំនៅប្រទេសកូរ៉េ បដិសេធមតមួយចំនួនសង្ស័យថា មានពលករខ្មែរផ្ទុកមេរោគ Coivd-19

KAMPUCHEA THMEY DAILY













## ស្ថានទូតខ្មែរប្រចាំនៅប្រទេសកូរ៉េ បដិសេធមតិមួយចំនួនសង្ស័យថា មានពលករខ្មែរផ្ទុកមេរោគ coivd-19

25/2/2020 4:06 Pm | ព័ត៌មានថ្មីៗ, សុខភាព | LIKE

ADVERTISER







ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសកូរ៉េខាងត្បូង បានជូនដំណឹងប្រជាពលរដ្ឋខ្មែរទាំងអស់ដែលកំពុងរស់នៅ ធ្វើការ និងសិក្សានៅប្រទេសកូរ៉េថា ករណីពលករខ្មែរម្នាក់ធ្វើការនៅតំបន់០៤១ ដែលត្រូវបានព័ត៌មាន និងមតិមួយចំនួនសង្ស័យថា មានផ្ទុកមេរោគកូរ៉ូណា Covid-19។ ប៉ុន្តែក្រោយពីក្រុមគ្រូពេទ្យជំនាញពិនិត្យរួចរាល់មក បញ្ជាក់ថា ពលករខាងលើនេះ មិនមានផ្ទុកនូវមេរោគកូរ៉ូណាទេ ហើយមកដល់ពេលនេះក៏មិនទាន់មានពលរដ្ឋខ្មែរណាម្នាក់មានផ្ទុកនូវមេរោគនេះដែរ។

ស្ថានទូតខ្មែរបានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរនៅប្រទេសកូរ៉េទាំងអស់ ប្រកបរបរទទួលទាន និងធ្វើការងារប្រចាំថ្ងៃជាធម្មតាតាមការកំណត់របស់រោងចក្រ សហគ្រាស កសិដ្ឋាន គ្រឹះស្ថានសិក្សា ឬស្ថាប័នផ្សេងៗ និងធ្វើតាមការណែនាំពីវិធីការពាររបស់អាជ្ញាធរកូរ៉េ និងជាពិសេសកុំជឿព័ត៌មានក្លែងក្លាយតាមបណ្តាញសង្គមខ្លះដែលមានលក្ខណៈបំផ្លិចបំភ័យខុសពីការពិតជាក់ស្តែង។

# ១១.កម្ពុជាថ្មី៖ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) បានចេញលិខិតស្តីពីបច្ចុប្បន្នភាពអំពី សកម្មភាពពាក់ព័ន្ធនឹងវីរុសកូរ៉ូណាថ្មី (COVID-19) គិតត្រឹមថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY

ប្រាសាក់ នៅតែបន្តដំឡើង អត្រាការប្រាក់បញ្ញើសន្សំ 8%
023 / 086 999 911 www.prasac.com.kh



Amret mobile ប្រតិបត្តិការធនាគារក្នុងដៃអ្នក






## វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (ipc) បានចេញលិខិតស្តីពីបច្ចុប្បន្នភាពអំពី សកម្មភាពពាក់ព័ន្ធនឹងវីរុសកូរ៉ូណាថ្មី (covid-19) គិតត្រឹមថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

25/2/2020 9:37 Pm ជាតិទូទៅ, ព័ត៌មានជាតិ, សុខភាព

LIKE

ADVERTISER

ACLEDA ToanChet
You can pay in Khmer Riel at Thailand via ACLEDA ToanChet conveniently.

855PLAY
078 855 855

ភ្នំពេញ ៖ នៅថ្ងៃអង្គារ៍ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ គ.ស ២០២០ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើការរួមគ្នាជាមួយក្រសួងសុខាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណាថ្មី (COVID-19) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ IPC ត្រូវបានចាត់តាំងដោយក្រសួងសុខាភិបាលកម្ពុជា ជាមន្ទីរពិសោធន៍ជួរមុខសម្រាប់ការធ្វើរោគវិនិច្ឆ័យរកវីរុសកូរ៉ូណាថ្មី (COVID-19)។

នេះបើយោងតាមលិខិតដែលវិទ្យាស្ថានប៉ាស្ទ័របានធ្វើការផ្សព្វផ្សាយ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០នេះ ដែលខ្លឹមសារទាំងស្រុងមាននៅក្នុងលិខិតខាងក្រោមនេះ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Institut Pasteur du Cambodge

**វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា**
លេខ: ០៣៥/IPC/DIR/២០២០

ថ្ងៃ អង្គារ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

**បច្ចុប្បន្នភាពអំពី សកម្មភាពពាក់ព័ន្ធនឹងវីរុសកូរ៉ូណាថ្មី (COVID-19)**
**គិតត្រឹម ថ្ងៃទី ២៥ កុម្ភៈ ២០២០**

វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) បានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើការរួមគ្នាជាមួយក្រសួងសុខាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណាថ្មី (COVID-19) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ IPC ត្រូវបានចាត់តាំងដោយក្រសួងសុខាភិបាលកម្ពុជា ជាមន្ទីរពិសោធន៍ជួរមុខ សម្រាប់ការធ្វើរោគវិនិច្ឆ័យរកវីរុសកូរ៉ូណាថ្មី (COVID-19)។

ដោយបានប្រើប្រាស់សមត្ថភាពមន្ទីរពិសោធន៍ មានជីវសុវត្ថិភាពកំរិតទី៣ (BLS-3–level) រួមជាមួយការវិភាគមន្ទីរពិសោធន៍មួយចំនួន យោងតាមការណែនាំបឋមរបស់ អង្គការសុខភាពពិភពលោក (WHO) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានអនុវត្ត បានពិនិត្យសុពលភាព និងធានាបាននូវសមត្ថភាពធ្វើរោគវិនិច្ឆ័យរក និងឆ្លើយតបទៅនឹងការឆ្លងវីរុសកូរ៉ូណាថ្មី (COVID-19) នៅក្នុងប្រទេសកម្ពុជា។ តាមរយៈការធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (CDC) នៃក្រសួងសុខាភិបាល ដែលជាអង្គភាពសម្របសម្រួល ទទួលបានការចាត់តាំង ក្នុងការរាយការណ៍ករណីសង្ស័យ វត្ថុវិភាគជាតម្រូវការចាំបាច់ និងបំពង់ក ពីករណីសង្ស័យទាំងនោះ ត្រូវបានបញ្ជូនទៅ IPC យ៉ាងទាន់ពេលវេលា និងត្រូវបានធ្វើការវិភាគភ្លាមៗ។ វត្ថុវិភាគទាំងអស់ត្រូវបានធ្វើវិភាគដោយ វិធីសាស្ត្រមន្ទីរពិសោធន៍ដែលមានសុពលភាព។ ករណីសង្ស័យ ត្រូវបានធ្វើតេស្តដោយច្រើនវិធីសាស្ត្រផ្សេងគ្នា ដើម្បីធានាបាននូវសុពលភាពលទ្ធផល។

នៅថ្ងៃទី២៧ ខែមករា IPC បានធ្វើតេស្តឃើញករណី ឆ្លងវីរុសកូរ៉ូណាថ្មី (COVID-19) ដំបូង និងតែមួយគត់ នៅប្រទេសកម្ពុជា ដែលជាអ្នកដំណើរពីទីក្រុងវូហានប្រទេសចិនមកប្រទេសកម្ពុជា។ គិតត្រឹមថ្ងៃទី២៥ ខែកុម្ភៈ នេះ ប្រព័ន្ធការងារ CDC/IPC ទទួលបានការរាយការណ៍ចំនួន ៥៥ ករណីសង្ស័យ (៦១ វត្ថុវិភាគ) និង៨ ករណីប៉ះពាល់ជិតស្និទ្ធ (១១ វត្ថុវិភាគ) តាមរយៈប្រព័ន្ធរាយការណ៍នេះ។

នៅថ្ងៃទី១២ ខែកុម្ភៈ IPC ត្រូវបានស្នើ អោយជួយគាំទ្រដល់ក្រសួងសុខាភិបាល ផ្នែកសកម្មភាពក្រៅប្រព័ន្ធរាយការណ៍ខាងលើ ដើម្បីអនុញ្ញាតអោយមានការចូលចត និងផ្ទេរអ្នកដំណើរពីនាវាទេសចរណ៍ វេស្ទើដាម (Westerdam)។ ដំបូងបង្អស់ វត្ថុវិភាគយកពីអ្នកដំណើរនាវាទេសចរណ៍វេស្ទើដាម ចំនួន ២០នាក់ ដែលមានរោគសញ្ញា ត្រូវបានធ្វើតេស្ត និង

# ១២. កោះសន្តិភាព៖ COVID-19 ៖ ចិនទទួលបានលទ្ធផលក្នុងការរាំងខ្ទប់ការឆ្លង






## COVID-19 ៖ ចិនទទួលបានលទ្ធផលក្នុងការរាំងខ្ទប់ការឆ្លង

ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ១៥:៥២ ខាន់ សុខយន Share Like 71




ប្រទេសចិន ៖ ក្រុមអ្នកជំនាញការរួមមួយ ដែលមានបណ្តាអ្នកជំនាញការចិន និងបណ្តាអ្នកជំនាញការរបស់អង្គការសុខភាពពិភពលោក WHO គូសបញ្ជាក់កាលពីថ្ងៃទី២៤កុម្ភៈថា អន្តរាគមន៍នានា របស់សុខាភិបាលសាធារណៈ ពុំធ្លាប់មានពីមុនមករបស់ចិន ប្រឈមមុខនឹងការឆ្លងរាលដាលនៃវីរុសCOVID-19ទទួលបានលទ្ធផលដ៏ធំធេង ក្នុងការរាំងខ្ទប់ការឆ្លងរវាងមនុស្សនិងមនុស្សនៃវីរុសនោះ ដោយយ៉ាងណាស់អាចបង្ការឬធ្វើឲ្យយឺតចំពោះការចម្លងដល់មនុស្សច្រើនរយពាន់នាក់។

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
| --- | --- |

អត្រាប្តូរប្រាក់ផ្សេងទៀត >

SPONSORED NEWS




ម្ចាស់ផ្ទះតាកែវ City Bird (A) ក្លាយជាជើងឯកមណ្ឌលតាកែវ នៃព្រឹត្តិការណ៍ Tiger Street Football 2020




ការវាយតម្លៃនេះត្រូវបានបង្ហាញក្នុងឱកាសនៃសន្និសីទសារព័ត៌មានមួយ នៅក្រុងប៉េកាំង បន្ទាប់ពីក្រុមរួមនោះនៃអ្នកជំនាញការនេះ ដែលមានសមាជិក២៥រូប បានធ្វើដំណើរសិក្សាមួយនៅលើទីលានអស់ពេល៩ថ្ងៃនៅចិន។ យោងតាមក្រុមនេះថា ចិនក៏ដើរតួនាទីសំខាន់មួយដែរក្នុងកិច្ចការពារសហគមន៍អន្តរជាតិ ដោយអាចឲ្យបណ្តាប្រទេសមានពេលដើម្បីប្រកាន់យក បណ្តាវិធានការដ៏សកម្ម ក្នុងការបង្ការនិងត្រួតពិនិត្យនិងផ្តល់បណ្តាបទពិសោធន៍។

ក្រុមនេះបន្តថាចិនបានចាត់បណ្តាវិធានការដោយប្រុងប្រយ័ត្ន ជាបន្តបន្ទាប់និងផៀបរយ ដើម្បីស្តារឡើងវិញជាបន្តបន្ទាប់ របៀបផៀបរយក្នុងផ្នែកសង្គម សេដ្ឋកិច្ចនិងសុខាភិបាល។ ប្រទេសដទៃៗទៀតត្រូវវាយតម្លៃឡើងវិញឲ្យបានឆាប់រហ័ស លើបណ្តាវិធានការដែលបានចាត់ចំពោះប្រទេសចិន៕ ដកស្រង់ចេញពីវេបសាយ ៖ xinhuanet (កែសម្រួលដោយ ៖ បុប្ផា)

# ១៣. ដើមអម្ពិល៖ លោក ដូណាល់ ត្រាំ៖ ការគំរាមកំហែងពីវីរុស កូរ៉ូណា នៅតែស្ថិតក្រោម ការគ្រប់គ្រងបាន នៅទូទាំងអាមេរិក



អូរ៉ូរ៉ា ស៊ីធី AURORA CITY (City Of Light)




ព័ត៌មានអន្តរជាតិ

## លោក ដូណាល់ ត្រាំ៖ ការគំរាមកំហែងពីវីរុស កូរ៉ូណា នៅតែស្ថិតក្រោម ការគ្រប់គ្រងបាន នៅទូទាំងអាមេរិក

By SS107

Posted on February 25, 2020

LASTEST NEWS
នយោបាយ
នាយករដ្ឋមន្ត្រី ណែនាំឱ្យប្រើប្រាស់ យន្តហោះរបស់ កម្ពុជា-ចិន សម្រាប់ដឹកវត្ថុធាតុដើម ពីចិនមកផ្គត់ផ្គង់ រោងចក្រនៅកម្ពុជា







175 Shares Share Pin Email Share Share

វ៉ាស៊ីនតោន៖ ប្រធានាធិបតីអាមេរិកលោក ដូណាល់ត្រាំ បានប្រកាសនៅក្នុងសារមួយថា វីរុសកូរ៉ូណា ឬ Covid-19 គឺស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងច្បាស់លាស់ នៅក្នុងសហរដ្ឋអាមេរិក។

យោងតាមសារព័ត៌មាន Sputnik ចេញផ្សាយកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ បានឱ្យដឹងថា លោក ត្រាំ ក៏បានកោតសរសើរផងដែរដល់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺអាមេរិក (CDC) និងអង្គការសុខភាពពិភពលោក (WHO) ចំពោះកិច្ចខិតខំប្រឹងប្រែងដ៏ធំធេងនិងឆ្លាតវៃរបស់ពួកគេ ក្នុងការការពារការផ្ទុះឡើងនូវវីរុសឆ្លងដែលមាន ដើមកំណើតនៅទីក្រុង វូហាន ប្រទេសចិន ពីការក្លាយជាការគំរាមកំហែងរបស់ពិភពលោក។

លោកថា «CDC និង និង អង្គការសុខភាពពិភពលោក បាននិងកំពុងធ្វើការយ៉ាងស្វាហាប់និងឆ្លាតវៃណាស់។ ផ្សារហ៊ុនចាប់ផ្តើមមើល ទៅល្អសម្រាប់ខ្ញុំ!»។

ទោះយ៉ាងណា ផ្សារភាគហ៊ុនអាមេរិក បានធ្លាក់ចុះយ៉ាងខ្លាំងកាលពីថ្ងៃច័ន្ទដោយ ធ្លាក់ចុះជាង ១,០០០ ពិន្ទុ ដោយសារករណីឆ្លងវីរុស ត្រូវបានកត់ត្រាដោយមន្ត្រីសុខាភិបាល ដែលជាហេតុធ្វើឱ្យមានការព្រួយបារម្ភថា ការរីករាលដាល នៃវីរុសនេះ នឹងនាំឱ្យមានការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ ប្រែសម្រួល: ណៃ គុណា

# ១៤. ដើមអម្ពិល៖ កូវីដ-១៩ នៅកូរ៉េខាងត្បូង កំពុងរំខានដល់ សភា ប្រព័ន្ធតុលាការ និងប្រតិបត្តិការរដ្ឋាភិបាល




សេអ៊ូល៖ ស្ថាប័ននីតិប្បញ្ញត្តិប្រព័ន្ធតុលាការ និងរដ្ឋបាល នៅកូរ៉េខាងត្បូង កាលពីថ្ងៃច័ន្ទបានព្យាយាមរារាំងការរីករាល ដាលនៃមេរោគឆ្លងថ្មី ដែលបង្ខំឱ្យស្ថាប័នរដ្ឋផ្អាក និងកាត់បន្ថយប្រតិបត្តិការ និងព្រឹត្តិការណ៍នានា។

រដ្ឋសភាបានបញ្ចប់សម័យប្រជុំពេញអង្គរបស់ខ្លួន និងបានបិទអាគាររសំខាន់ៗរបស់ខ្លួនជាបណ្ដោះអាសន្ន ដែលនេះអាចជាលើកទីមួយ បន្ទាប់ពីត្រូវបានគេរកឃើញថា មានមនុស្សម្នាក់ដែលឆ្លងវីរុសនេះបានចូលរួមក្នុងវេទិការសភាកាលពីសប្ដាហ៍មុន។

អាជ្ញាធរតុលាការ បានអំពាវនាវឱ្យមានការពន្យារពេល ដែលមិនធ្លាប់មានពីមុននៃការសាកល្បងបន្ទាន់ ហើយក្នុងនោះក្រសួងរដ្ឋាភិបាល បានលុបចោល និងកាត់បន្ថយចំនួនការប្រជុំ ដំណើរទស្សនកិច្ច និងព្រឹត្តិការណ៍សារព័ត៌មាននានា និងរឹតបន្តឹងនីតិវិធីចូលនៅតាមការិយាល័យរដ្ឋ។
ដោយ ឈូក បូរ៉ា

# ១៥.ដើមអម្ពិលៈចិនបណ្តេញអ្នកកាសែតរបស់ Wall Street Journal ៣នាក់ចេញពីប្រទេស ដោយសារផ្សាយរឿង ប្រទេសចិន គឺជាអ្នកជំងឺពិតប្រាកដរបស់អាស៊ី




ព័ត៌មានអន្តរជាតិ

## ចិនបណ្តេញអ្នកកាសែតរបស់ Wall Street Journal ៣នាក់ចេញពីប្រទេស ដោយសារផ្សាយរឿង ប្រទេសចិន គឺជាអ្នកជំងឺពិតប្រាកដរបស់អាស៊ី

By VNT108

Posted on February 25, 2020

Shares

បរទេស៖ អ្នកយកព័ត៌មាន២រូប ក្នុងចំណោមអ្នកយកព័ត៌មាន ៣រូប របស់កាសែត Wall Street Journal ដែលមានមូលដ្ឋាននៅចិនដីគោក ដែលលិខិតបញ្ជាក់សារព័ត៌មានរបស់ខ្លួន ត្រូវបានដកហូតកាលពីសប្តាហ៍មុន ដោយសារតែការចេញផ្សាយអត្ថបទមួយ ដែលមានចំណងជើងថា “ ប្រទេសចិន គឺជាអ្នកជំងឺពិតប្រាកដរបស់អាស៊ី” បានចាកចេញពីប្រទេសកាលពីថ្ងៃច័ន្ទ។

▼ Advertisement by Synergy E ▼

យោងតាមសារព័ត៌មាន Sputnik ចេញផ្សាយនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ បានឱ្យដឹងថា អត្ថបទវិចារណកថាដ៏ចម្រូងចម្រាស ដែលត្រូវបានសរសេរដោយ Walter Russell Mead និងត្រូវបានបោះពុម្ពផ្សាយ នៅថ្ងៃទី ៣ ខែកុម្ភៈ បានអះអាងថា អាជ្ញាធរចិន កំពុងព្យាយាមលាក់បាំងទំហំពិត នៃការឆ្លងវីរុសជំងឺ COVID-១៩ ហើយពួកគេនៅតែបន្តតស៊ូ ដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺនេះ និងចាប់ផ្តើមសេដ្ឋកិច្ច របស់ពួកគេឡើងវិញ។

បុគ្គលិកទាំងនោះ ត្រូវបានកំណត់អត្តសញ្ញាណ ដោយកាសែត Wall Street Journal ជាជនជាតិអាមេរិក, ជាអនុប្រធាន ការិយាល័យក្រុងប៉េកាំងរបស់ចិន លោក Josh Chin និងអ្នកយកព័ត៌មានលោក Chao Deng ក៏ដូចជាលោក Philip Wen ជនជាតិអូស្ត្រាលី។ អ្នកទាំង ៣ មានពេល ៥ថ្ងៃ ដើម្បីចាកចេញពីប្រទេស បន្ទាប់ពីការប្រកាសថ្ងៃទី ១៩ ខែកុម្ភៈ។

ការសម្រេចចិត្តរបស់ប្រទេសចិន ក្នុងការបណ្តេញ អ្នកយកព័ត៌មានទាំងបីនាក់នេះ គឺត្រូវបានទទួលការរិះគន់យ៉ាងខ្លាំង នៅសហរដ្ឋអាមេរិក។ សេចក្តីថ្លែងការណ៍ផ្លូវការមួយ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលបានចេញផ្សាយកាលពីថ្ងៃពុធសប្តាហ៍មុន បានថ្កោលទោស ចំពោះការបណ្តេញចេញនេះ ដោយកត់សម្គាល់ថា“ ប្រទេសដែលមានភាពចាស់ទុំ និងមានការទទួលខុសត្រូវ ត្រូវយល់ អំពីអង្គហេតុសេរីភាព នៃការរាយការណ៍ព័ត៌មាន និងការបញ្ចេញមតិ” ។ ប្រែសម្រួល: ណៃ គុលា

# ១៦.កម្ពុជាថ្មី៖ អ្នកនាំពាក្យថា ជំងឺផ្លូវដង្ហើម COVID-19 មិនមែនជារឿងចិនម្នាក់ឯងទេ តែជាបញ្ហារួមនៅលើពិភពលោក

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY













## អ្នកនាំពាក្យថា ជំងឺផ្លូវដង្ហើម covid-19 មិនមែនជារឿងចិនម្នាក់ឯងទេ តែជាបញ្ហារួមនៅលើពិភពលោក

25/2/2020 5:24 Pm ជាតិទូទៅ, ព័ត៌មានជាតិ, សុខភាព

ADVERTISER






ភ្នំពេញ ៖ លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានអះអាងថា ជំងឺផ្លូវដង្ហើម ដែលមកពីវីរុសកូរ៉ូណា (COVID-19) នេះ មិនមែនជារឿងចិនម្នាក់ឯងទេ តែគឺជាបញ្ហារួមនៅក្នុងតំបន់ និងនៅលើពិភពលោក ហើយការប្រជុំរួមអាស៊ាន-ចិន គឺជាការងារសមស្របមួយ ដើម្បីពិភាក្សារកដំណោះស្រាយរួម ឲ្យមានប្រសិទ្ធភាពសម្រាប់ពិភពលោក។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជារូបនោះអះអាងយ៉ាងនេះថា “ជំងឺផ្លូវដង្ហើមកូវីដ១៩ មិនមែនជារឿងចិនម្នាក់ឯងទេ តែគឺជាបញ្ហារួមនៅក្នុងតំបន់ និងនៅលើពិភពលោក។ ការប្រជុំរួមអាស៊ាន ចិន គឺជាការសមស្រប ដើម្បីពិភាក្សារកដំណោះស្រាយសមស្រប និងមានប្រសិទ្ធភាព”។ ទោះជាយ៉ាងណា ពួកប្រឆាំងជ្រុលនិយមមួយចំនួន ដែលកំពុងលាក់ខ្លួននៅបរទេស តែងតែនិយាយបន្តុះបង្អាប់ថា ប្រព័ន្ធសុខាភិបាលកម្ពុជាខ្សោយ តែជាក់ពិតមេរោគកូវីដ១៩ ដែលគេតែងនិយាយពីករណីកប៉ាល់វេសស្ទ័រដាំ (Westerdam) នោះ មិនបានចម្លងនៅកម្ពុជាទេ ហើយស្ត្រីជនជាតិអាមេរិកាំងវ័យ៨៣ឆ្នាំ ប្រសិនបើមានមេរោគកូវីដ១៩ នោះ ពិតជាចម្លងទៅប្តី ដែលមានអាយុ ៨៤ឆ្នាំជាក់ជាមិនខាន។

ចំណែកប្រតិកម្មរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាចំពោះរដ្ឋាភិបាលម៉ាឡេស៊ីរឿងធ្វើតេស្តលើស្ត្រីអាមេរិកាំងនៅលើនាវាវេស្ទ័រដាំនោះ គឺដើម្បីយុត្តិធម៌របស់ សម្តេចតេជោ ហ៊ុន សែន និងប្រជាជនកម្ពុជាទាំងមូល និងការពិតដែលត្រូវពួកអគតិតែងតែនិយាយមួលបង្កាច់។ ឥឡូវក្លាយចេញការពិតហើយ គឺការពិតស្ថិតនៅលើស្ត្រីជនជាតិអាមេរិកាំង និងអ្នកស្ថិតនៅក្នុងនាវាវេសស្ទ័រដាំ អត់មានអ្នកស្លាប់ អត់មានអ្នកណាឆ្លងទាល់តែសោះ។ អ្វីដែលកាន់តែច្បាស់ទៀតនោះ សមត្ថកិច្ចអាមេរិក បានបញ្ជាក់ថា លោកយាយអាយុ៨៣ឆ្នាំ ដែលម៉ាឡេស៊ីថា មានឆ្លងវីរុសកូរូណាកូវីដ ១៩នោះ គឺអត់ដែលមានឆ្លងវីរុសកូវីដ១៩នេះទេ នៅពេលកន្លងមក។

គួរបញ្ជាក់ថា បើតាមរបាយការណ៍ប្រចាំថ្ងៃដោយអាជ្ញាធរសុខាភិបាលចិន មនុស្សស្លាប់ដោយសារតែជំងឺឆ្លង COVID-19 នៅទូទាំងប្រទេសបានកើនឡើងដល់ ២,៦៦៣នាក់ និងអ្នកដែលបានឆ្លងជំងឺនេះសរុបកើនដល់ ៧៧,៦៥៨ករណី ហើយដែលចំនួនទាំងនេះមានការថមថយ ប៉ុន្តែករណីឆ្លងថ្មីបែរជាកើនឡើងទៅវិញ ដោយក្នុងនោះ អ៊ីរ៉ាក់ អាហ្វហ្គានីស្ថាន គុយវ៉ែត អូម៉ង់ និងបារ៉ែន នៅថ្ងៃចន្ទសប្តាហ៍នេះបានអះអាងដូចៗគ្នា ពីការរកឃើញករណីឆ្លងជំងឺ COVID-19 ជាលើកដំបូងនៅក្នុងប្រទេសរបស់ពួកគេរៀងៗខ្លួន។

ចំណែកអង្គការសុខភាពពិភពលោក (WHO) បានប្រកាស កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ថា ពិភពលោកគួរតែត្រៀមខ្លួនឲ្យហើយ ដើម្បីប្រឈមមុខនឹងលទ្ធភាពផ្ទុះឡើង នៃជំងឺ COVID-19 ទៅជាជំងឺរាតត្បាតសកល។ ការប្រកាសបែបនេះធ្វើឡើងបន្ទាប់ពីជំងឺឆ្លងមួយនេះ បាននិងកំពុងរីករាលកាន់តែខ្លាំងនៅក្នុងប្រទេសកូរ៉េខាងត្បូង អ៊ីតាលី និងអ៊ីរ៉ង់ នេះបើតាមការចេញផ្សាយដោយសារព័ត៌មាន BBC។

ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅថ្ងៃច័ន្ទ ដើមសប្តាហ៍នេះ ប្រធានអង្គការ WHO លោក ថេដ្រូស ហ្គេប្រេយ៉េសីស (Tedros Adhanom Ghebreyesus) បានបញ្ជាក់ថា ការកើនឡើងចំនួនករណីឆ្លង COVID-19 នារយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ នៅក្នុងប្រទេសអ៊ីរ៉ង់ អ៊ីតាលី និងកូរ៉េខាងត្បូង គឺជារឿងមួយគួរឲ្យព្រួយបារម្ភ។ លោកបន្តថា វាដូចជាលឿនហើសពេកក្នុងការចាត់ទុកថា COVID-19 គឺជា “ជំងឺរាតត្បាតសកលលោក” ប៉ុន្តែបណ្តាប្រទេសទាំងអស់នៅលើពិភពលោក គួរតែត្រៀមខ្លួនឲ្យហើយ។

អត្ថបទ ៖ កោះកែវ

# ១៧. កម្ពុជាថ្មី៖ ទារិកាអាយុ ១៧ ថ្ងៃជាអ្នកជំងឺកូវីដណាក្មេងជាងគេដែលបានជាសះស្បើយ

KAMPUCHEA THMEY DAILY



ទំព័រដើម | ព័ត៌មាន | KPT PLUS | កម្សាន្ត | កីឡា | សុខភាព | បច្ចេកវិទ្យា | ហោរាសាស្ត្រ



Home › KPT Plus › ទារិកាអាយុ ១៧ ថ្ងៃជាអ្នកជំងឺកូវីដណាក្មេងជាងគេដែលបានជាសះស្បើយ



## ទារិកាអាយុ ១៧ ថ្ងៃជាអ្នកជំងឺកូវីដណាក្មេងជាងគេដែលបានជាសះស្បើយ

25/2/2020 4:20 Pm KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព LIKE

ADVERTISER






ទារិកាអាយុ ១៧ ថ្ងៃបានជាសះស្បើយពីវីរុស Covid-19 បន្ទាប់ពីនាងបានឆ្លងពីម្ដាយនៅថ្ងៃសម្រាលនៅមន្ទីរពេទ្យក្រុងអ៊ូហាន។ ប្រព័ន្ធផ្សព្វផ្សាយចិនបានរាយការណ៍ថា ទារិកានេះជាអ្នកជំងឺវ័យក្មេងបំផុតដែលបានជាសះស្បើយពីវីរុសនៅក្នុងប្រទេស។ នាងបានចេញពីមន្ទីរពេទ្យកាលពីថ្ងៃសុក្រ បន្ទាប់ពីជាសះស្បើយដោយមិនចាំបាច់ប្រើថ្នាំ។

យោងតាមសារព័ត៌មាន People's Daily បានឲ្យដឹងថា ទារិកានេះត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យកុមារ Wuhan ក្នុងថ្ងៃតែមួយនៅថ្ងៃដែលនាងកើត។ នាងត្រូវបានគេរកឃើញថាមានផ្ទុកវីរុស Covid-19 បន្ទាប់ពីសម្រាលបាន ៣០ ម៉ោង។

វេជ្ជបណ្ឌិត Zeng Lingkong បាននិយាយថា ទារិកានេះឈ្មោះ Xiao Xiao ។ នាងមិនត្រឹមតែរកឃើញថាបានឆ្លងឆ្លងវីរុស Covid-19 ប៉ុណ្ណោះទេ ប៉ុន្តែនាងក៏បញ្ហាប្រព័ន្ធដង្ហើម និងខូចប្រព័ន្ធចង្វាក់បេះដូងផងដែរ។ ដោយសារតែបែបនេះទើបគ្រូពេទ្យសម្រេចចិត្តមិនដាក់ថ្នាំផ្សះ (antibiotic) ឱ្យនាង និងទុកឲ្យនាងយកឈ្នះជំងឺនេះដោយខ្លួនឯង។

នៅរសៀលថ្ងៃសុក្រសប្ដាហ៍មុន បន្ទាប់ពីទទួលលទ្ធផលអវិជ្ជមានក្នុងការធ្វើតេស្តរកវីរុស Covid-19 នាងត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ។ លោកវេជ្ជបណ្ឌិត Zeng បាននិយាយថា Xiao Xiao បានជាសះស្បើយពីជំងឺកូវីដណា និងបានជាពីជំងឺបេះដូងដែរ។

ចុចអាន៖ វៀតណាមប្រកាស អ្នកមានផ្ទុកវីរុស Covid-19 ទាំង ១៦ នាក់ក្នុងប្រទេសខ្លួនបានជាសះស្បើយអស់ហើយ

**ប្រែសម្រួល៖ សន្យា**

## ១៨. កម្ពុជាថ្មី៖ សាលានៅហុងកុងបន្តបិទទ្វារយ៉ាងហោចដល់ពាក់កណ្តាលខែមេសាដោយសារការផ្ទុះនៃវីរុស Covid-19

កម្ពុជាថ្មី ប្រចាំថ្ងៃ KAMPUCHEA THMEY DAILY









ADVERTISER







# សាលានៅហុងកុងបន្តបិទទ្វារយ៉ាងហោចដល់ពាក់កណ្តាលខែមេសាដោយសារការផ្ទុះនៃវីរុស covid-19

25/2/2020 2:44 Pm KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព

LIKE

នៅថ្ងៃអង្គារនេះរដ្ឋាភិបាលចិនបានប្រកាស ពីការបិទទ្វារសាលារៀននៅហុងកុង ដោយក្នុងនោះ មតេយ្យសិក្សា បឋមសិក្សា និងអនុវិទ្យាល័យនឹងត្រូវពន្យាពេលឈប់សម្រាករហូតដល់ពាក់កណ្តាលខែមេសា។ ទោះយ៉ាងណាមន្ត្រីអប់រំថា ខ្លួននៅចង់ធ្វើតេស្តសម្រាប់ការប្រលងចូលសាកលវិទ្យាល័យដូចដែលបានគ្រោងទុកគឺនៅថ្ងៃទី ២៧ ខែមីនាខាងមុខ។

ដោយសារតែការផ្ទុះឡើងនៃវីរុស Covid-19 នៅក្នុងទីក្រុង ការិយាល័យអប់រំកាលពីដើមខែកុម្ភៈនេះបានបន្ថែមការផ្អាកថ្នាក់រៀននៅតាមសាលាមត្តេយ្យ និងគ្រប់សាលាទាំងអស់។ អ្វីដែលជាក្តីព្រួយបារម្ភគឺថា នៅឆ្នាំនេះសិស្សដែលនឹងប្រឡងចូលសាកលវិទ្យាល័យមានចំនួន ៥២ ពាន់នាក់។ បើសិនតាមសាលានានាក៏ដូចជាសាកលវិទ្យាល័យបន្តបិទទ្វារបែបនេះ វាអាចនឹងប៉ះពាល់ដល់សិស្សដែលកំពុងត្រៀមខ្លួនចូលមហាវិទ្យាល័យ។

ក្នុងពេលតឹងតែងនេះមន្ត្រីអប់រំមានគម្រោងជម្រើស២។ ជម្រើសទី១គឺបន្តការប្រឡងតែមុខវិជ្ជា២-៣ ប៉ុណ្ណោះ ប៉ុន្តែរក្សាកាលវិភាគដើមដែលនឹងចាប់ផ្តើមប្រឡងនៅថ្ងៃទី ២៧ ខែមីនា។ ជម្រើសទី ២ គឺពន្យារពេលការប្រឡងរយៈពេលមួយខែដោយចាប់ផ្តើមនៅថ្ងៃទី ២៤ ខែមេសាជំនួសវិញ និងលុបចោលមុខវិជ្ជាភាសាចិន ភាសាអង់គ្លេស និងការប្រឡងផ្ទាល់មាត់។

ប្រភពបាននិយាយថា មន្ត្រីអប់រំទំនងជាជ្រើសរើសយកជម្រើសទី ១ ពីព្រោះវានឹងបង្កឱ្យមានការរំខានតិចតួចសម្រាប់និស្សិតនិងអាជ្ញាធរទទួលបន្ទុកការប្រឡង។

គេរំពឹងថា លេខាធិការក្រសួងអប់រំលោក Kevin Yeung Yun-hung និងអគ្គលេខាធិការគ្រួតពិនិត្យនិងវាយតម្លៃហុងកុងលោក So Kwok-sang នឹងប្រកាសសេចក្តីសម្រេចចិត្តរសៀលថ្ងៃអង្គារនេះ។

**ចុចអាន៖ ករណី COVID-19 ច្រើនបំផុតក្រៅអាស៊ី! ស្លាប់ ៧ នាក់និងជាង ២២០ នាក់ឆ្លងនៅអ៊ីតាលី**

**ចុចអាន៖ ព្រឹកនេះអ្នកឆ្លងកូរ៉ូណានៅកូរ៉េខាងត្បូងឡើងខ្ពស់ជិត ៩០០នាក់ ក្រោយរកឃើញករណីថ្មី ៦០ នាក់ទៀតយប់មិញ**

**ប្រែសម្រួល៖ សន្យា**